**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិដឹកនាំការងារ**
**កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ**
លេខ ......០០.៨......./គ.ជ.ក.វ

*រាជធានីភ្នំពេញ ថ្ងៃទី...១១.....ខែ.........ឆ្នាំ២០០៧*

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមគាំទ្រកម្មវិធី ដែលផ្ទេរពីកម្មវិធីសិលា មកក្រោមការគ្រប់គ្រងរបស់ គ.ជ.ក.វ

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៧/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦ នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការរៀបចំការបង្កើតក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញប្រកាសលេខ០៩៥ ប្រ.ក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ

## ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមគាំទ្រកម្មវិធី សម្រាប់សម្របសម្រួលការអនុវត្តការងារដែលបានផ្ទេរមកពីកម្មវិធីសិលា នៅក្រោមលេខាធិការដ្ឋាន គ.ជ.ក.វ ដែលរួមមាន ផ្នែកហិរញ្ញវត្ថុ ផ្នែកគ្រប់គ្រងកិច្ចសន្យា និង

សម្របសម្រួលគម្រោង ផ្នែករដ្ឋបាលកម្មវិធី និងផ្នែកតាមដានត្រួតពិនិត្យវាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ ។

**ប្រការ ២.-**

ក្រុមគាំទ្រកម្មវិធី ត្រូវមានសមាសភាពដឹកនាំដូចខាងក្រោម :

១- ឯកឧត្តម **ឈឿង យ៉ាណារ៉ា** អគ្គលេខាធិការរង ក.អ.ក និងជាអនុប្រធានក្រុមការងារ គ.ជ.វ.វ ជានាយកក្រុមគាំទ្រកម្មវិធី

២- ឯកឧត្តម **លេខ ទី** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងជាប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជានាយករងទី១ នៃក្រុមគាំទ្រកម្មវិធី

៣- ឯកឧត្តម **ម៉ាន់ ចំរើន** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជា ជានាយករងទី២ នៃក្រុមគាំទ្រកម្មវិធី

៤- លោក **ឡាយ ណារុធ** អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ ជាប្រធានផ្នែកហិរញ្ញវត្ថុ នៃក្រុមគាំទ្រកម្មវិធី

៥- លោក **យិន ម៉ាលីណា** អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាប្រធានផ្នែករដ្ឋបាលកម្មវិធី នៃក្រុមគាំទ្រកម្មវិធី

៦- លោក **នី គឹមសាន** ប្រធានការិយាល័យស្រាវជ្រាវបច្ចេកទេស នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យា និងសម្របសម្រួលគម្រោង នៃក្រុមគាំទ្រកម្មវិធី

៧- លោក **ប្រាក់ សំអឿន** ប្រធានការិយាល័យតាមដាន ត្រួតពិនិត្យ និងគាំទ្រឃុំ សង្កាត់ នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាប្រធានផ្នែកតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយគោលនយោបាយ នៃក្រុមគាំទ្រកម្មវិធី

៨- លោក **ស៊ី ទរិន** ប្រធានការិយាល័យហិរញ្ញវត្ថុឃុំ សង្កាត់ នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសវនាករផ្ទៃក្នុង នៃក្រុមគាំទ្រកម្មវិធី

៩- លោក **ឈិន សេខខួន** ប្រធានការិយាល័យអប់រំ និងកសាងសមត្ថភាព នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ជាសវនាករផ្ទៃក្នុង នៃក្រុមគាំទ្រកម្មវិធី

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួន ក្រុមគាំទ្រកម្មវិធីត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវ ជាមួយ គ.ជ.វ.វ ក្រុមការងារ គ.ជ.វ.វ និងលេខាធិការដ្ឋាន គ.ជ.វ.វ។ ដូច្នេះ ដើម្បីធានាបាននូវគណនេយ្យភាពនេះ ចាំបាច់ត្រូវមានការបែងចែកការទទួលខុសត្រូវដូចខាងក្រោម :

**ក. គ.ជ.វ.វ**

គ.ជ.វ.វ ត្រូវមានការទទួលខុសត្រូវលើដំណើរការនៃកម្មវិធីទាំងមូល ស្របទៅតាមក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីនយោបាយ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ការទទួលខុសត្រូវ

ជាក់ស្តែងរបស់ គ.ជ.វ.វ មានជាអាទិ៍ :

- ដឹកនាំផ្នែកគោលនយោបាយ និងគោលការណ៍ណែនាំដល់ក្រុមគាំទ្រកម្មវិធី

- ពិនិត្យ អនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ

- ពិនិត្យ អនុម័តលើកិច្ចព្រមព្រៀង អនុស្សារណៈ និងឯកសារប្រហាក់ប្រហែល ក្នុងការទទួលជំនួយគាំទ្រជាមួយដៃគូអភិវឌ្ឍន៍នានា

- សម្រេចអំពីរចនាសម្ព័ន្ធ ប្រព័ន្ធ និងតម្រូវការបុគ្គលិកនៃក្រុមគាំទ្រកម្មវិធី

- សម្រេចតែងតាំងនាយក នាយករង និងប្រធានតាមផ្នែកនីមួយៗ នៃក្រុមគាំទ្រកម្មវិធី និងសវនករផ្ទៃក្នុង

- កំណត់អំពីកម្រិតប្រាក់ឧបត្ថម្ភដល់មន្ត្រីក្រុមគាំទ្រកម្មវិធីតាមប្រភេទនីមួយៗ

- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា នូវរាល់ភារកិច្ចទាំងឡាយណា ដែលក្រុមគាំទ្រកម្មវិធី លេខាធិការដ្ឋាន គ.ជ.វ.វ និងក្រុមការងារ គ.ជ.វ.វ មិនអាចសម្របសម្រួលបាន។

### ខ. ក្រុមការងារ គ.ជ.វ.វ

- ដឹកនាំ សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានា លើកិច្ចការទាំងអស់ដែលត្រូវដាក់ជូន គ.ជ.វ.វ ពិនិត្យ សម្រេច

- កំណត់អំពីគោលការណ៍ណែនាំ និងនីតិវិធីនៃការជ្រើសរើសបុគ្គលិកក្រុមគាំទ្រកម្មវិធី និងមន្ត្រីគាំទ្រ (Supporting Staffs) ដល់ផ្នែកគាំទ្រគោលនយោបាយ

- ពិនិត្យ សម្រេចលើទីប្រឹក្សាជាតិ និងអន្តរជាតិទាំងអស់

- ដឹកនាំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ

- ដឹកនាំការពិនិត្យ វាយតម្លៃកម្មវិធីរៀងរាល់០៦ខែម្តង។

### គ. លេខាធិការដ្ឋាន គ.ជ.វ.វ

- ពិនិត្យ សម្របសម្រួល និងផ្តល់យោបល់លើឯកសារផ្សេងៗ ដែលក្រុមគាំទ្រកម្មវិធីស្នើសុំការពិនិត្យសម្រេចពីក្រុមការងារ គ.ជ.វ.វ និង គ.ជ.វ.វ ដើម្បីឱ្យឆ្លើយតបទៅនឹងគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល

- ពិនិត្យ និងដោះស្រាយកិច្ចការផ្សេងៗដែលក្រុមគាំទ្រកម្មវិធីមិនអាចដោះស្រាយបាន

- ទទួលខុសត្រូវរាល់កិច្ចលទ្ធកម្មដែលមានតម្លៃចាប់ពី ២០.០០០ដុល្លារអាមេរិកឡើង

- ពិនិត្យ សម្រេចពីកិច្ចសន្យាការងារ និងលក្ខខណ្ឌការងាររបស់មន្ត្រីនៃក្រុមគាំទ្រកម្មវិធី និងមន្ត្រីគាំទ្រ (Supporting Staffs) នៃផ្នែកគាំទ្រគោលនយោបាយ

- ផ្តល់គោលការណ៍ដឹកនាំទូទៅដល់ក្រុមគាំទ្រកម្មវិធី តាមការប្រគល់ភារកិច្ចពី គ.ជ.វ.វ និងក្រុមការងារ គ.ជ.វ.វ។

### ឃ. ក្រុមគាំទ្រកម្មវិធី

- ដឹកនាំការងារប្រចាំថ្ងៃ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំនានាដែលសម្រេចដោយ គ.ជ.វ.វ និងត្រូវទទួលខុសត្រូវផ្ទាល់ចំពោះមុខ គ.ជ.វ.វ ក្រុមការងារ គ.ជ.វ.វ និងលេខាធិការដ្ឋាន គ.ជ.វ.វ

- ធ្វើកិច្ចសហប្រតិបត្តិការជាប្រចាំជាមួយដៃគូអភិវឌ្ឍន៍នានា និងរៀបចំរបាយការណ៍រីកចំរើនការងារ

និងហិរញ្ញវត្ថុ វាយតម្លៃពីការអនុវត្តគម្រោង និងឯកសារផ្សេងៗទៀត ដល់ដៃគូអភិវឌ្ឍន៍ តាមការកំណត់នៅក្នុងកិច្ចព្រមព្រៀងផ្តល់ជំនួយ

- ធ្វើកិច្ចសហប្រតិបត្តិការឱ្យបានល្អ នៅក្នុងពេលធ្វើសវនកម្មគម្រោង និងបេសកកម្មពិនិត្យពីវឌ្ឍនភាពគម្រោង និងបេសកកម្មផ្សេងៗទៀតរបស់ដៃគូអភិវឌ្ឍន៍នានា

- ពិនិត្យ តាមដាន វាយតម្លៃ ការអនុវត្តលក្ខខណ្ឌការងារនៃបុគ្គលិកក្រុមគាំទ្រកម្មវិធី ដែលមានចែងក្នុងកិច្ចសន្យាការងារ

- អនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ និងទទួលខុសត្រូវក្នុងការធ្វើប្រតិបត្តិការផ្ទេរថវិកាគម្រោង ដើម្បីគាំទ្រដល់ថ្នាក់ក្រោមជាតិ

- ចាត់ចែងការងាររដ្ឋបាលប្រចាំថ្ងៃ គ្រប់គ្រងយានយន្ត គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ បណ្ណាល័យ ទំនាក់ទំនងផ្តល់ទទួលព័ត៌មាន

- ការពិនិត្យ តាមដានការអនុវត្តការងាររបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង

- ទទួលខុសត្រូវលើកិច្ចលទ្ធកម្មនានាដែលមានតម្លៃក្រោម២០.០០០,០០ដុល្លាអាមេរិក

- ដឹកនាំ សម្របសម្រួលទីប្រឹក្សាបច្ចេកទេស ស្របតាមការព្រមព្រៀងរវាង គ.ជ.វ.វ និងដៃគូអភិវឌ្ឍន៍ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងតាមដានការអនុវត្តលក្ខខណ្ឌការងាររបស់ទីប្រឹក្សាទាំងនោះផង

- ធ្វើរបាយការណ៍ជាប្រចាំ និងតាមការកំណត់របស់ គ.ជ.វ.វ ក្រុមការងារ គ.ជ.វ.វ និងលេខាធិការដ្ឋាន គ.ជ.វ.វ។

**ប្រការ ៤.-**

ក្រសួង ស្ថាប័នជាសមាជិក គ.ជ.វ.វ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងឯកឧត្តម អស់លោកដែលមានឈ្មោះនៅក្នុងប្រការ១ ខាងលើនេះ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ ៥.-**

បទប្បញ្ញត្តិរបស់ គ.ជ.វ.វ ទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ស ខេង

**កន្លែងទទួល :**

- ក្រសួងសមាជិក គ.ជ.វ.វ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈកម្មការប្រតិបត្តិគ្រប់ខេត្ត ក្រុង
- ដៃគូអភិវឌ្ឍន៍ UNDP DFID SIDA (ដើម្បីជូនជ្រាប)
- សាមីខ្លួន (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ